គណបក្សប្រជាជនកម្ពុជា
គណៈកម្មាធិការកណ្ដាល

លេខ ១២៥៤/១៥ សស.គក

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

ភ្នំពេញ, ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៥

# សេចក្ដីសម្រេច

## ស្ដីពីការកែសម្រួលភារកិច្ច សិទ្ធិអំណាច រចនាសម្ព័ន្ធចាត់តាំង និងរបៀបរបបធ្វើការរបស់គណៈកម្មាធិការត្រួតពិនិត្យគណបក្ស ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

......................

**យោង** : - លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងគណបក្សប្រជាជនកម្ពុជា
- សេចក្ដីកំណត់លេខ ០០៧ ស.ស.រ.ម.ឈ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ១៩៨៦
- សេចក្ដីសម្រេចលេខ ១០២៥/១៥ សស.គក ចុះថ្ងៃទី ០១ ខែតុលា ឆ្នាំ២០១៥ ស្ដីពីការកែសម្រួលតួនាទី ភារកិច្ច សិទ្ធិអំណាច រចនាសម្ព័ន្ធ ចាត់តាំង និងរបៀបរបបធ្វើការរបស់គណៈកម្មាធិការត្រួតពិនិត្យ គណៈកម្មាធិការកណ្ដាល
- ស្មារតីអង្គប្រជុំគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាល នាថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៥។

## គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្ដាល
## សម្រេច

**ប្រការ១**: កែសម្រួលតួនាទី ភារកិច្ច សិទ្ធិអំណាច រចនាសម្ព័ន្ធ និងរបៀបរបបធ្វើការរបស់គណៈកម្មាធិការត្រួតពិនិត្យគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដូចខាងក្រោម ៖

**ក.តួនាទី**

គណៈកម្មាធិការត្រួតពិនិត្យគណបក្សក្រសួងស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជាស្ថាប័នជំនួយការរបស់គណៈកម្មាធិការគណបក្សថ្នាក់នីមួយៗ មានតួនាទីត្រួតពិនិត្យការអនុវត្តលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កម្មវិធីនយោបាយ គោលការណ៍ គោលនយោបាយ និងសេចក្ដីសម្រេចចិត្តនានារបស់គណបក្ស និងស្រាវជ្រាវ ត្រួតពិនិត្យចំពោះមន្ត្រី និងអង្គការចាត់តាំងគណបក្ស ស្ថិតក្រោមការគ្រប់គ្រងរបស់គណៈ

កម្មាធិការគណបក្សថ្នាក់ខ្លួន ដែលបានប្រព្រឹត្តល្មើស ខុសឆ្គង។

**ខ.ភារកិច្ច**

១-តាមដាន និងជំរុញការដឹកនាំរបស់អង្គការចាត់តាំង និងមន្ត្រី សមាជិកគណបក្ស ចំណុះគណៈកម្មាធិការគណបក្សថ្នាក់ខ្លួន ក្នុងការអនុវត្តលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កម្មវិធីនយោបាយ សេចក្តីសម្រេចចិត្ត សារាចរ សេចក្តីណែនាំរបស់គណបក្ស ឲ្យសម្រេចបានជោគជ័យ និងមានប្រសិទ្ធភាព។

២-ត្រួតពិនិត្យអង្គការចាត់តាំង មន្ត្រីគណបក្ស និងសមាជិកគណបក្ស ដែលស្ថិតក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការគណបក្សថ្នាក់ខ្លួន ដែលល្មើសលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង វិន័យរបស់គណបក្ស ច្បាប់រដ្ឋ និងលក្ខណសម្បត្តិរបស់មន្ត្រីគណបក្ស ឬសមាជិកគណបក្ស។

៣-ទទួល និងដោះស្រាយបណ្តឹងបរិហារ និងបណ្តឹងតវ៉ាចំពោះអង្គការចាត់តាំង ឬមន្ត្រី សមាជិកគណបក្ស ដែលស្ថិតក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការគណបក្សថ្នាក់ខ្លួន។

៤-តាមដាន ត្រួតពិនិត្យការដាក់វិន័យ និងការអនុវត្តវិន័យ ចំពោះមន្ត្រី ឬសមាជិកគណបក្សរបស់អង្គការចាត់តាំងគណបក្សថ្នាក់ក្រោម។

៥-ត្រួតពិនិត្យហិរញ្ញវត្ថុរបស់អង្គការចាត់តាំងគណបក្សថ្នាក់ក្រោម តាមការប្រគល់ភារកិច្ចរបស់គណៈកម្មាធិការគណបក្សថ្នាក់ខ្លួន។

៦-ណែនាំគណៈកម្មាធិការត្រួតពិនិត្យគណបក្សថ្នាក់ក្រោម ឲ្យអនុវត្តបានត្រឹមត្រូវតាមតួនាទី ភារកិច្ច ការងារត្រួតពិនិត្យរបស់ថ្នាក់ខ្លួន។

៧-សហការជាមួយគណៈចាត់តាំង និងបណ្តាស្ថាប័នរបស់គណបក្សដែលស្ថិតក្រោមចំណុះគណៈកម្មាធិការគណបក្សថ្នាក់ខ្លួន ក្នុងការស្នើសុំតែងតាំងមន្ត្រីគណៈកម្មាធិការត្រួតពិនិត្យថ្នាក់ក្រោម និងសម្រេចឲ្យបានល្អប្រសើរនូវភារកិច្ចការងារត្រួតពិនិត្យរបស់គណបក្ស។

៨- សិក្សាស្រាវជ្រាវ លើកកម្ពស់សមត្ថភាព ផ្លាស់ប្តូរបទពិសោធន៍ អំពីមុខជំនាញការងារត្រួតពិនិត្យ និងណែនាំដល់មន្ត្រីត្រួតពិនិត្យថ្នាក់ក្រោម។

៩-ទទួលអនុវត្តភារកិច្ចពាក់ព័ន្ធដទៃទៀត ដែលគណៈប្រចាំការ ឬគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការគណបក្សថ្នាក់ខ្លួនប្រគល់ជូន។

**គ.សិទ្ធិអំណាច**

- តាមដាន និងលើកមតិជូនគណៈកម្មាធិការគណបក្ស ក្នុងការលើកសរសើរអង្គការចាត់តាំង ឬមន្ត្រីគណបក្ស ស្ថិតក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការគណបក្សថ្នាក់ខ្លួន ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច។

- លើកមតិក្នុងការដាក់វិន័យចំពោះអង្គការចាត់តាំង ឬមន្ត្រីគណបក្ស ស្ថិតក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការគណបក្សថ្នាក់ខ្លួន ដែលបានប្រព្រឹត្តល្មើសលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង វិន័យគណបក្ស ច្បាប់រដ្ឋ និងលក្ខណសម្បត្តិរបស់មន្ត្រី ឬសមាជិកគណបក្ស។

- លើកមតិជូនគណៈកម្មាធិការគណបក្សថ្នាក់ខ្លួន ដើម្បីពិនិត្យសម្រេចយល់ព្រម ឬផ្លាស់ប្តូរ ឬលុបសេចក្តីសម្រេចរបស់អង្គការចាត់តាំងគណបក្សថ្នាក់ក្រោមក្នុងការអនុវត្តវិន័យ និងដាក់វិន័យសមាជិក និងអង្គការចាត់តាំងគណបក្ស ចំពោះករណី ២ យ៉ាង ដូចខាងក្រោម ៖

១-ដោះស្រាយពាក្យបណ្តឹងតវ៉ា អំពីការដាក់វិន័យចំពោះមន្ត្រី ឬសមាជិកគណបក្ស ដែលអង្គការចាត់តាំងគណបក្សថ្នាក់ក្រោមបានសម្រេច។

២-ត្រួតពិនិត្យការអនុវត្តវិន័យរបស់អង្គការចាត់តាំងគណបក្សថ្នាក់ក្រោម ក្នុងពេលដែលពិនិត្យឃើញថា ការអនុវត្តការដាក់វិន័យពុំទាន់បានត្រឹមត្រូវតាមសេចក្តីសម្រេចរបស់គណបក្ស។

- ត្រួតពិនិត្យការងាររបស់គណៈកម្មាធិការត្រួតពិនិត្យថ្នាក់ក្រោម។

- សំណូមពរឲ្យអង្គការចាត់តាំងគណបក្សថ្នាក់ក្រោម បណ្តាស្ថាប័ន និងមន្ត្រី ឬសមាជិកគណបក្សដែលពាក់ព័ន្ធរាយការណ៍ ឬផ្តល់ឯកសារចាំបាច់សម្រាប់ការងារត្រួតពិនិត្យ។

**ឃ.រចនាសម្ព័ន្ធ**

- គណៈកម្មាធិការត្រួតពិនិត្យគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អាស្រ័យដោយសន្និបាតពេញអង្គនៃគណៈកម្មាធិការគណបក្សថ្នាក់ខ្លួនបោះឆ្នោតជ្រើសតាំងឡើង ហើយត្រូវបានគណៈកម្មាធិការគណបក្សថ្នាក់លើយល់ព្រមទទួលស្គាល់។

- ក្នុងស្ថានភាពចាំបាច់ជាក់ស្តែង ដើម្បីឲ្យការងារត្រួតពិនិត្យរបស់គណបក្សដំណើរការសម្រេចបានលទ្ធផលល្អ និងមាននិរន្តរភាព គណៈកម្មាធិការគណបក្សថ្នាក់នីមួយៗ អាចធ្វើសំណើទៅគណៈកម្មាធិការគណបក្សថ្នាក់លើផ្ទាល់ ដើម្បីស្នើតែងតាំងគណៈកម្មាធិការត្រួតពិនិត្យគណបក្សថ្នាក់ខ្លួន។

១.<u>គណៈកម្មាធិការត្រួតពិនិត្យគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន</u>

គណៈកម្មាធិការត្រួតពិនិត្យគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន មានចំនួន ៩ រូប ដែលមានសមាសភាពដូចខាងក្រោម ៖

- ប្រធាន ជាសមាជិកអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស
- អនុប្រធាន ជាសមាជិកគណៈកម្មាធិការគណបក្ស

- សមាជិក ១ រូប ជាសមាជិកគណៈកម្មាធិការគណបក្ស ដែលជាមន្ត្រីទទួលបន្ទុកការងារបុគ្គលិក ចាប់ពីថ្នាក់អនុប្រធាននាយកដ្ឋានឡើងទៅ
- សមាជិក ១ រូប ជាប្រធាន ឬអនុប្រធានអធិការកិច្ច
- សមាជិក ១ រូបទៀត ទទួលជំនាញផ្ទាល់។

២.គណៈកម្មាធិការត្រួតពិនិត្យគណៈកម្មាធិការគណបក្សរាជធានី ខេត្ត

គណៈកម្មាធិការត្រួតពិនិត្យគណបក្សរាជធានី ខេត្ត មានចំនួន ៥ រូប ចំពោះខេត្តធំ ឬមធ្យម និងមានចំនួន ៣ រូប ចំពោះខេត្តតូច ដែលមានសមាសភាពដូចខាងក្រោម ៖

គណៈកម្មាធិការត្រួតពិនិត្យដែលមានចំនួន ៥ រូប

- ប្រធាន ជាសមាជិកអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស
- អនុប្រធាន ជាសមាជិកគណៈកម្មាធិការគណបក្ស
- សមាជិក ១ រូប ជាសមាជិកគណៈកម្មាធិការគណបក្សទទួលបន្ថែម (ជាប្រធាន ឬអនុប្រធានគណៈចាត់តាំង)
- សមាជិក ១ រូប ជាប្រធាន ឬអនុប្រធានមន្ទីរអធិការកិច្ច
- សមាជិក ១ រូប ទទួលជំនាញផ្ទាល់។

គណៈកម្មាធិការត្រួតពិនិត្យដែលមានចំនួន ៣ រូប

- ប្រធាន ជាសមាជិកអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស
- អនុប្រធាន ជាសមាជិកគណៈកម្មាធិការគណបក្ស
- សមាជិក ១ រូប ទទួលបន្ថែម (ជាប្រធាន ឬអនុប្រធានគណៈចាត់តាំង)។

**+ គណៈកម្មាធិការត្រួតពិនិត្យគណបក្សរាជធានី ខេត្ត អាចមានមន្ត្រីជំនួយការ ២ ឬ ៣ រូប។**

៣.គណៈកម្មាធិការត្រួតពិនិត្យគណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ

គណៈកម្មាធិការត្រួតពិនិត្យគណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ មានចំនួន ៣ រូប ដែលមានសមាសភាពដូចខាងក្រោម ៖

- ប្រធាន ជាសមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស
- អនុប្រធាន ជាសមាជិកគណៈកម្មាធិការគណបក្ស
- សមាជិកទទួលបន្ថែម (ជាប្រធាន ឬអនុប្រធានគណៈចាត់តាំង)។

**+ គណៈកម្មាធិការត្រួតពិនិត្យគណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ អាចមានមន្ត្រីជំនួយការចំនួន ១ ឬ ២ រូប ។**

៤.អង្គការចាត់តាំងមូលដ្ឋានរបស់គណបក្ស

-ប្រធានគណៈកម្មាធិការគណបក្សមូលដ្ឋានឃុំ សង្កាត់ និងថ្នាក់ប្រហាក់ប្រហែល ទទួលបន្ទុកការងារត្រួតពិនិត្យ និងមានមន្ត្រីជំនួយការ ១ រូប ។

**ខ.របៀបរបបធ្វើការ**

- គណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ ធ្វើការក្រោមការដឹកនាំរបស់គណៈកម្មាធិការគណបក្ស នៅថ្នាក់របស់ខ្លួន។

- គណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ ធ្វើការតាមរបបសមូហភាព និងសម្រេចតាមមតិភាគច្រើនដាច់ខាត នៃគណៈកម្មាធិការត្រួតពិនិត្យទាំងមូល។

- គណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ ត្រូវមានរបបប្រជុំឲ្យបានទៀងទាត់ ត្រូវរាយការណ៍អំពីសភាពការណ៍ និងសុំយោបល់ណែនាំពីគណៈអចិន្ត្រៃយ៍ គណៈកម្មាធិការគណបក្សថ្នាក់ខ្លួន។

-ផ្អែកតាមសេចក្តីសម្រេចនេះ គណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ ត្រូវលើកផែនការសកម្មភាព និងកសាងបទវិន័យផ្ទៃក្នុង រៀបចំមន្ត្រីជំនួយការរបស់ខ្លួន ដើម្បីជានាអនុវត្តការកិច្ចឲ្យបានល្អ និងមានប្រសិទ្ធភាព។

-គណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ ត្រូវអនុវត្តឲ្យបានត្រឹមត្រូវនូវរបបរាយការណ៍តាមកាលកំណត់ (ប្រចាំខែ ត្រីមាស ឆមាស ឆ្នាំ) ជូនគណៈកម្មាធិការត្រួតពិនិត្យថ្នាក់លើរបស់ខ្លួន។

**ប្រការ២**: សេចក្តីកំណត់ពីមុន ដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។ អង្គការចាត់តាំង និងសមាសភាពគណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ ដែលបានរៀបចំរួចហើយ ត្រូវរក្សាទុកដដែលរហូតដល់មានការរៀបចំជាថ្មី តាមសេចក្តីសម្រេចនេះ។

**ប្រការ៣**: ខុទ្ទកាល័យ គណៈចាត់តាំង គណៈកម្មាធិការត្រួតពិនិត្យ នៃគណៈកម្មាធិការកណ្តាល គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវប្រតិបត្តិតាមសេចក្តីសម្រេចនេះ។/

**ជ.គណៈអចិន្ត្រៃយ៍**

**ប្រធាន**

**ហ៊ុន សែន**